**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០៤/០៧-០៩-២០០៩-អវតក/កសចស(អបជ)
**ដាក់ទៅ** : អង្គបុរេជំនុំជម្រះ
**ថ្ងៃដាក់** : ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញាអន្តរជាតិ
**ភាសាដើម** : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 29-Jun-2015, 15:41
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** សម្ងាត់
**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ:** សម្ងាត់/Confidential
**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**
**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:**
**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**
**ហត្ថលេខា:**

---

# ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីកាសម្រេចដាក់ឲ្យគាត់ស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញាអន្តរជាតិ**
លោក Nicholas KOUMJIAN

**ចម្លងជូន:**
**សហព្រះរាជអាជ្ញាជាតិ**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Steven J. BWANA
ចៅក្រម ន័យ ថុល
ចៅក្រម Olivier BEAUVALLET
ចៅក្រម ហួត វុទ្ធី

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៃ**
**សំណុំរឿង០០៤**

**ចម្លងជូន:**
**សហមេធាវី អ៊ឹម ចែម:**
ប៊ិត ស៊ាងលឹម
John R.W.D. JONES QC

សហមេធាវី អោ អាន:
មុំ លុជ្ស
Göran SLUITER
Richard ROGERS

## I. សេចក្តីផ្តើម

1. អ៊ឹម ចែម បានដាក់បណ្តឹងឧទ្ធរណ៍[1]ជំទាស់ទៅនឹងដីកាសម្រេច[2]របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Mark Harmon ("សចស អន្តរជាតិ") ដែលបានដាក់ឲ្យគាត់ស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*។ នៅក្នុងដីកាសម្រេចនោះ សចស អន្តរជាតិយល់ឃើញយ៉ាងត្រឹមត្រូវថា អង្គហេតុនៃសំណុំរឿងនេះ បានបង្ហាញនូវបញ្ហាមួយដែលមិនត្រូវបានដោះស្រាយដោយវិធានផ្ទៃក្នុង[3]។ បន្ទាប់មកគាត់បានស្វែងរកគោលការណ៍ណែនាំត្រឹមត្រូវចំពោះបញ្ហានេះ នៅក្នុងវិធាននីតិវិធីដែលត្រូវបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។ ដោយបានធ្វើដូច្នេះ គាត់បានសន្និដ្ឋានយ៉ាងសមរម្យថា ការដាក់ឲ្យ អ៊ឹម ចែម ស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* គឺជាវិធីតែមួយគត់ ដើម្បីធានាឲ្យបាននូវកិច្ចដំណើរការនីតិវិធីដោយត្រឹមត្រូវ និងឆាប់រហ័ស និងដើម្បីការពារសិទ្ធិរបស់ អ៊ឹម ចែម, ជនរងគ្រោះ, និងប្រជាជនកម្ពុជា[4]។ ដីកាសម្រេចដាក់ឲ្យស្ថិតក្រោមការពិនិត្យត្រូវបានសម្រេចឡើយយ៉ាងត្រឹមត្រូវ និងស្របទៅនឹងច្បាប់ពាក់ព័ន្ធទាំងអស់។ ជាងនេះទៅទៀត អ៊ឹម ចែម ខកខានមិនបានលើកឡើងនូវភាពអយុត្តិធម៌ណាមួយ ដែលកើតចេញពីដីកាសម្រេចដាក់ឲ្យស្ថិតក្រោមការពិនិត្យនោះទេ។ តាមពិត ដីកាសម្រេចដាក់ឲ្យស្ថិតក្រោមការពិនិត្យផ្តល់ឲ្យគាត់នូវសិទ្ធិច្រើនជាងមុនទៀត មិនមែនតិចជាងមុននោះទេ។ ដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិ ("សហព្រះរាជអាជ្ញា") សុំស្នើឲ្យបដិសេធបណ្តឹងឧទ្ធរណ៍នេះ។

## II. ប្រវត្តិនីតិវិធី

---

[1] **D239/1/2** បណ្តឹងឧទ្ធរណ៍ អ៊ឹម ចែម ប្រឆាំងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០១៥ ("បណ្តឹងឧទ្ធរណ៍") *បានជូនដំណឹងដល់ ក.ស.ព នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥។*

[2] **D239** ដីកាសម្រេចដាក់ អ៊ឹម ចែម ឲ្យស្ថិតនៅក្រោមការពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ("ដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ")។

[3] ដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ កថាខណ្ឌ៥៧។ *សូមមើល* វិធាន២ នៃវិធានផ្ទៃក្នុង។

[4] ដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ កថាខណ្ឌ៥៧-៧៥។ *សូមមើល* ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ អ.វ.ត.ក") មាត្រា ២៣ ថ្មី។

2. កិច្ចស៊ើបសួរតាមផ្លូវតុលាការប្រឆាំងនឹង អ៊ឹម ចែម បានចាប់ផ្ដើមនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ ដោយមានការដាក់សេចក្ដីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[5]។ អ៊ឹម ចែម ត្រូវបានជូនដំណឹងអំពីឋានៈរបស់ខ្លួនជាជនសង្ស័យនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២[6]។ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤ ដីកាកោះមួយត្រូវបានបញ្ជូនដោយផ្ទាល់ទៅឱ្យ អ៊ឹម ចែម ដែលតម្រូវឱ្យរូបគាត់ចូលរួមក្នុងការបង្ហាញខ្លួនលើកដំបូង ដែលត្រូវបានគ្រោងទុកនៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៤[7]។ នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ មេធាវីការពារក្ដីរបស់ អ៊ឹម ចែម បានជូនដំណឹងដល់ សចស អន្តរជាតិថា អ៊ឹម ចែម នឹងមិនឆ្លើយតបទៅនឹងដីកាកោះនោះទេ[8]។

3. នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ សចស អន្តរជាតិបានចេញដីកាបង្គាប់ឱ្យនាំខ្លួន ដើម្បីធានាឱ្យបានថា អ៊ឹម ចែម មានវត្តមាននៅក្នុងពេលបង្ហាញខ្លួនលើកដំបូង។ ដីកាបង្គាប់ឱ្យនាំខ្លួននេះត្រូវបានបញ្ជូនទៅនគបាលយុត្តិធម៌កម្ពុជានៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤[9]។ មកទល់ពេលនេះ ដីកានេះមិនទាន់ត្រូវបានអនុវត្តនោះទេ[10]។

4. ដោយពិចារណាលើព្រឹត្តិការណ៍ទាំងនេះ សចស អន្តរជាតិ បានវាយតម្លៃពីផលប៉ះពាល់លើការវិវឌ្ឍន៍របស់កិច្ចដំណើរការនីតិវិធីនៃ “ការខកខានដោយចេតនារបស់ អ៊ឹម ចែម ដែលមិនបានចូលបង្ហាញខ្លួនលើកដំបូង ឬក៏ការខកខានរបស់នគបាលយុត្តិធម៌ដែលមិនបានអនុវត្តដីកានាំខ្លួនឱ្យបានឆាប់រហ័ស ដោយឥតពន្យារពេលដើម្បីនាំគាត់មកបង្ហាញខ្លួននៅចំពោះមុខតុលាការនោះ”។ គាត់

---

[5] **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨។ **D1/1** សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទីអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣ ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ ។ ដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ កថាខណ្ឌ១។

[6] **D108** ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន២១(១)ឃ] ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២។ ដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ កថាខណ្ឌ២។

[7] **A150** ដីកាកោះឱ្យបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤។ ដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ កថាខណ្ឌ១១។

[8] ជាក់ច្បាស់នោះ អ៊ឹម ចែម បានបញ្ជាក់ថា គាត់មិនអាចឆ្លើយតបទៅនឹងដីកាកោះដែលត្រូវបានចុះហត្ថលេខាដោយ សចស អន្តរជាតិតែម្នាក់ឯងនោះទេ។ **A150/2** កំណត់ត្រារបស់ សចស អន្តរជាតិទាក់ទងនឹងការបង្ហាញខ្លួនលើកដំបូងរបស់ អ៊ឹម ចែម ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៦។ ដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ កថាខណ្ឌ២០។

[9] **C1** ដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤។ **C1.1** របាយការណ៍ស្ដីពីការបញ្ជូនដីកាបង្គាប់ឱ្យនាំខ្លួនទៅកាន់នគបាលយុត្តិធម៌ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤។ ដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ កថាខណ្ឌ២១។

[10] ដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ កថាខណ្ឌ ២៣-៣០។

បានសម្រេចថា ការខកខានទាំងនេះនឹងរារាំងសហចៅក្រមស៊ើបអង្កេត ក្នុងការបំពេញការទទួលខុសត្រូវរបស់ខ្លួនដើម្បីបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿងលេខ០០៤ ហើយការខកខានទាំងនេះក៏នឹងរារាំងគោលបំណងរបស់ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ផងដែរ។ គាត់ក៏បានសម្រេចទៀតថា ការពន្យារពេលបន្ថែមទៀតនឹងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ អ៊ឹម ចែម ក្នុងការចូលរួមក្នុងកិច្ចស៊ើបសួរតាមផ្លូវតុលាការ និងសិទ្ធិក្នុងការមានពេលវេលា និងសម្ភារៈគ្រប់គ្រាន់ដើម្បីរៀបចំការការពារខ្លួនរបស់គាត់។ ជាចុងក្រោយគាត់បានសម្រេចថា ការពន្យារពេលបន្ថែមទៀតនឹង "ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិជនរងគ្រោះ និងប្រជាជនកម្ពុជា ហើយអាចនាំឱ្យមិនមានការគោរពដល់ អ.វ.ត.ក ដែលជាផ្នែកមួយពិសេស និងសំខាន់នៅក្នុងប្រព័ន្ធតុលាការកម្ពុជា"[11]។

5. ក្រោយពីបានធ្វើការវិភាគនេះ គាត់បានសន្និដ្ឋានថា ការដាក់ឱ្យ អ៊ឹម ចែម ស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* គឺជា "វិធីតែមួយគត់ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីអនុវត្តបានដោយយុត្តិធម៌ និងបានឆាប់រហ័ស"[12]។ ដីកាសម្រេចដាក់ឱ្យស្ថិតក្រោមការពិនិត្យនេះ ដែលរួមមានការជូនដំណឹងអំពីបទចោទប្រកាន់លម្អិត ត្រូវបានបញ្ជូនទៅកាន់ភាគីទាំងឡាយ ដោយរួមទាំងមេធាវីការពារក្តី អ៊ឹម ចែម ដែល អ៊ឹម ចែម បានជ្រើសរើសឱ្យតំណាងគាត់[13]។ បន្ទាប់ពីបានពិនិត្យដីកាសម្រេចដាក់ឱ្យស្ថិតក្រោមការពិនិត្យរួចមក តាមរយៈមេធាវីការពារក្តីរបស់គាត់ អ៊ឹម ចែម បានដាក់បណ្តឹងឧទ្ធរណ៍ភ្លាម[14]។

## III. ច្បាប់ជាធរមាន

### ក. ភាពអាចទទួលយកបាន

[11] ដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ កថាខណ្ឌ៧០-៧២។

[12] ដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ កថាខណ្ឌ៧៣។

[13] ដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ, គ្រប់ទំព័រ។ **D239.1** ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំងនឹង អ៊ឹម ចែម។ **D122/11** ដីកាសម្រេចទទួលស្គាល់មេធាវីតំណាងជនសង្ស័យ អ៊ឹម ចែម ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤។ **D122/13/1** ដីកាសម្រេចទទួលស្គាល់សហមេធាវីអន្តរជាតិតំណាង អ៊ឹម ចែម ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៤។

[14] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១, ១២។

6. ទោះបីជាវិធាន២១ នៃវិធានផ្ទៃក្នុងមិនបានកំណត់ឱ្យបានជាក់លាក់អំពីយុត្តាធិការបណ្តឹងឧទ្ធរណ៍របស់អង្គជំនុំជម្រះណាមួយក៏ដោយ ក៏អង្គបុរេជំនុំជម្រះ ("អង្គបុរេ") បានលើកឡើងពីមុនមកថា "វិធាន២១ តម្រូវថាអង្គបុរេជំនុំជម្រះត្រូវបកស្រាយឱ្យបានទូលំទូលាយនូវសិទ្ធិរបស់ជនត្រូវចោទក្នុងការប្តឹងឧទ្ធរណ៍ ដើម្បីធានាថា សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ត្រូវបានគាំពារ"[15]។

7. វិធាន៧៤(៣)(ក) នៃវិធានផ្ទៃក្នុងចែងថា "ជនត្រូវចោទ ឬជនជាប់ចោទ" អាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដោយអនុលោមតាមយុត្តាធិការរបស់ អ.វ.ត.ក។[16]

## ខ. អង្គសេចក្តី

8. វិធាន២ នៃវិធានផ្ទៃក្នុងចែងក្នុងផ្នែកដូចខាងក្រោម៖

> នៅក្នុងអំឡុងពេលដំណើការរបស់អង្គជំនុំជម្រះវិសាមញ្ញ *ប្រសិនបើមានបញ្ហាណាមួយកើតមានឡើងដែលមិនមានចែងក្នុង[វិធានផ្ទៃក្នុងនេះ]* ... សហចៅក្រមស៊ើបអង្កេត...ត្រូវធ្វើការសម្រេចចិត្ត ដោយស្របទៅលើមាត្រា ១២ (១) នៃកិច្ចព្រមព្រៀង និងមាត្រា ... ២៣ ថ្មី ... នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងដោយផ្តោតការយកចិត្តទុកដាក់ជាពិសេស ទៅលើគោលការណ៍ជាមូលដ្ឋានដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុងនេះ និងច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមាន។ ក្នុងករណីនេះ សំណើសុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុង ត្រូវដាក់ជូនទៅគណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុងឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន[17]។

9. មាត្រា ១២ (១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាចែងថា៖

---

[15] សំណុំរឿងលេខ០០២ ឯកសារ **D390/1/2/4** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់ លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើការនីតិវិធី ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី") កថាខណ្ឌ១៣។

[16] វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិសោធនកម្មលើកទី៩ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង") វិធាន៧៤(៣)(ក)។

[17] វិធាន២ នៃវិធានផ្ទៃក្នុង (គូសបញ្ជាក់បន្ថែម)។

នីតិវិធីត្រូវសមស្របជាមួយច្បាប់កម្ពុជា។ *នៅពេលណាដែលច្បាប់កម្ពុជា ពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងទៅនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិបែបនេះ ទៅនឹងបទដ្ឋានអន្តរជាតិគេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ*[18]។

10. ស្រដៀងគ្នានេះដែរ មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងដោយផ្នែកថា៖

> រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀតជាបរទេស ដែលហៅថា "សហចៅក្រមស៊ើបអង្កេត" ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន។ *ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ* ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ *សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ*[19]។

## IV. **បទដ្ឋាននៃការពិនិត្យឡើងវិញ**

11. បទដ្ឋាននៃការពិនិត្យឡើងវិញបានសរសេរយ៉ាងត្រឹមត្រូវនៅក្នុងបណ្តឹងឧទ្ធរណ៍[20]។

## V. **សេចក្តីសន្និដ្ឋាន**

### ក. ភាពអាចទទួលយកបាន

12. ដោយសារតែ អ៊ឹម ចែម ត្រូវបានពិចារណាយ៉ាងត្រឹមត្រូវថាជាជនត្រូវចោទមួយរូប នោះសហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា បណ្តឹងសាទុក្ខនេះគឺអាចទទួលយកបាន ដោយអនុលោមតាមវិធាន៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។

---

[18] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង អសប-រវក") មាត្រា១២(១) (គូសបញ្ជាក់បន្ថែម)។

[19] ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ *ដែលត្រូវបានធ្វើវិសោធនកម្ម*នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ("ច្បាប់ អ.វ.ត.ក") មាត្រា២៣ថ្មី (គូសបញ្ជាក់បន្ថែម)។

[20] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ ៣០។

## ខ. អង្គសេចក្ដី

### *១. ការខកខានរបស់ អ៊ឹម ចែម ក្នុងការចូលមកបង្ហាញខ្លួននៅក្នុងកិច្ចដំណើរការនីតិវិធី បង្កើតបានជាសំណួរមួយដែលមិនអាចដោះស្រាយបានក្នុងវិធានផ្ទៃក្នុង*

13. បណ្ដឹងឧទ្ធរណ៍នេះ ដំបូងគឺវិលត្រឡប់ទៅរកបញ្ហាថាតើ នៅក្នុងកាលៈទេសៈនៃករណីនេះ "មានបញ្ហាណាមួយកើតមានឡើង ដែលមិនមានចែងក្នុងវិធានផ្ទៃក្នុងនេះ" ដែរ ឬទេ[21]។ ចម្លើយទៅនឹងសំណួរនេះគឺ ច្បាស់ជាបញ្ជាក់ថាមាន។

14. វិធានផ្ទៃក្នុង បានរៀបរាប់ពី ដីកាកោះ ថាជា "*ការបង្គាប់* ដល់បុគ្គលណាម្នាក់ ឱ្យចូលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ"[22]។ ដូច្នេះ វិធានផ្ទៃក្នុងបានមើលឃើញ ដីកាកោះមានលក្ខណៈភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ហើយបានគិតបម្រុងទុកថានឹងត្រូវបានគេអនុវត្តតាម។ ក្នុងករណីនេះ អ៊ឹម ចែម ខកខានមិនបានអនុវត្តតាមដីកាកោះមួយដែលភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ទេ។

15. វិធានផ្ទៃក្នុងនេះ ក៏បានគិតបម្រុងទុកផងដែរថា ដីកាបង្គាប់ឱ្យនាំខ្លួន នឹងត្រូវបានគេប្រតិបត្តិតាមជាបន្ទាន់[23]។ នៅក្នុងករណីនេះ ដីកាបង្គាប់ឱ្យនាំខ្លួន អ៊ឹម ចែម មិនទាន់ត្រូវបានគេប្រតិបត្តិតាមទេ។

16. ដូច្នេះ ស្ថានភាពអង្គហេតុបច្ចុប្បន្ននេះ គឺមិនមែនគ្រាន់តែមិនបានប្រមើលមើលទុកជាមុនដោយវិធានផ្ទៃក្នុងទេ។ តែវាបែរជាផ្ទុយទៅនឹងស្ថានភាពអង្គហេតុដោយផ្ទាល់ ដែលត្រូវបានប្រមើលមើលទុកជាមុនដោយវិធានផ្ទៃក្នុងទៅវិញ។ វាចាំបាច់ត្រូវតាមដានមើលថាតើស្ថានភាពនេះ បង្កើតបានជាបញ្ហាមួយដែលមិនមានចែងក្នុងវិធានផ្ទៃក្នុងនេះដែរ ឬទេ។

### *២. មិនមាននីតិវិធីជាធរមាននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដោះស្រាយពីស្ថានភាពអង្គហេតុដែលបានបង្ហាញនៅក្នុងសំណុំរឿងនេះទេ*

17. ដូចជាវិធានផ្ទៃក្នុងដូច្នោះដែរ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("ក្រមនីតិវិធីព្រហ្មទណ្ឌ") បានផ្តល់អំណាចឱ្យចៅក្រមស៊ើបសួរចេញដីកាបង្គាប់ជាចាំបាច់ដល់បុគ្គលណាម្នាក់ឱ្យមកបង្ហាញខ្លួន[24]។

---

[21] វិធាន ២ នៃវិធានផ្ទៃក្នុង។

[22] វិធាន ៤១ នៃវិធានផ្ទៃក្នុង (សង្កត់ន័យដោយ *អក្សរទ្រេត*)។

[23] វិធាន ៤៥(២) នៃវិធានផ្ទៃក្នុង។

[24] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា១៨៦-១៨៨។

ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានចែងផងដែរថាឲ្យចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឲ្យនាំខ្លួន និងឲ្យឃុំខ្លួនបណ្ដោះអាសន្ន ដីកាទាំងនោះនឹងត្រូវបានគេប្រតិបត្តិតាម[25]។

18. នីតិវិធីជាធរមាននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមិនបានដោះស្រាយស្ថានភាពអង្គហេតុបច្ចុប្បន្ននេះទេ ដែលនៅក្នុងនោះ ដីកាបង្គាប់ឲ្យចូលមកបង្ហាញខ្លួនមួយមិនត្រូវបានគេធ្វើតាម ហើយដីកាបង្គាប់ឲ្យនាំខ្លួនមួយមិនត្រូវបានគេប្រតិបត្តិតាមនោះទេ។ ដោយសារតែស្ថានភាពនេះបានបង្កើតឡើងជាបញ្ហានានាដែលមិនបានប្រមើលមើលទុកជាមុនដោយវិធានផ្ទៃក្នុង ឬដោយក្រម នីតិវិធីព្រហ្មទណ្ឌក៏ដោយ ក៏វានៅតែមានលក្ខណៈសមស្របទៅតាមច្បាប់ជាធរមានរបស់តុលាការអន្តរជាតិ CIJ ក្នុងការពិនិត្យមើលវិធាននីតិវិធីនានាដែលបានបង្កើតឡើងនៅតាមកម្រិតអន្តរជាតិសម្រាប់ឆ្លើយតបទៅនឹងសំណួរនេះ[26]។

*៣. នៅក្រោមវិធានដែលបានបង្កើតសម្រាប់តុលាការ STL, អ៊ឹម ចែម ត្រូវបានចាត់ទុកថាបានចូលមកបង្ហាញខ្លួននៅក្នុងកិច្ចដំណើរការនីតិវិធីនេះរួចជាស្រេចទៅហើយ ដោយសារតែការចូលរួមចំណែកយ៉ាងសកម្មរបស់គាត់ តាមរយៈក្រុមមេធាវីការពារក្ដីដែលគាត់បានជ្រើសរើសដោយផ្ទាល់។ ដូច្នេះ ការចោទប្រកាន់លើរូបគាត់ មិនត្រូវបានគិតថា* ដោយកំបាំងមុខ *នោះទេ។*

19. វិធាន១០៤ នៃវិធានស្ដីពីភស្តុតាង និងនីតិវិធីរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ ("STL") ចែងថា៖ "កិច្ចដំណើរកានីតិវិធីមិនត្រូវចាត់ទុកថាដោយកំបាំងមុខទេ បើជនជាប់ចោទចូលមកបង្ហាញខ្លួនដោយបុគ្គលផ្ទាល់ តាមរយៈកិច្ចប្រជុំតាមរយៈវីឌីអូ ឬដោយមេធាវីការពារក្ដីដែលបានចាត់តាំង ឬបានទទួលស្គាល់ដោយជនជាប់ចោទរូបនោះ"[27]។

20. វិធាននេះគឺប្រកបទៅដោយអត្ថន័យ ពីព្រោះបុគ្គលម្នាក់ដែលបង្ហាញខ្លួននៅក្នុងកិច្ចដំណើរការនីតិវិធីតាមរយៈមេធាវីការពារក្ដីមានគុណវុឌ្ឍិតាមការជ្រើសរើសរបស់ខ្លួន គឺមិនមែន "អវត្តមាន" ពីកិច្ចដំណើរការនីតិវិធី ក្នុងន័យមានអត្ថន័យនោះឡើយ។ កិច្ចនេះគឺច្បាស់ណាស់នៅក្នុងករណីរបស់

---

[25] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា១៩៥-១៩៩។

[26] វិធាន ២ នៃវិធានផ្ទៃក្នុង។ កិច្ចព្រមព្រៀងរវាង អសប-រាជរដ្ឋាភិបាលកម្ពុជា, មាត្រា ១២(១)។ ច្បាប់ អវតក, មាត្រា ២៣ថ្មី។

[27] វិធានស្ដីពីភស្តុតាង និងនីតិវិធី, តុលាការពិសេសសម្រាប់ប្រទេសលីបង់ ("វិធានសម្រាប់តុលាការ STL"), វិធាន១០៤។

អ៊ឹម ចែម៖ គាត់បានជ្រើសរើសមេធាវីការពារក្ដីដោយខ្លួនគាត់ផ្ទាល់[28] គាត់ធ្វើការប្រាស្រ័យទាក់ទងជាមួយមេធាវីការពារក្ដីអំពីរឿងក្ដី និងផ្ដល់ការណែនាំដល់មេធាវី[29] ហើយគាត់ចូលរួមចំណែកយ៉ាងសកម្មនៅក្នុងរឿងក្ដីតាមរយៈមេធាវី[30]។ គាត់ក៏បានដឹងផងដែរអំពីកិច្ចដំណើរការនីតិវិធីដែលប្រឆាំងនឹងរូបគាត់ និងបទចោទនានាដែលគាត់ត្រូវប្រឈមមុខ៖ មេធាវីការពារក្ដីរបស់គាត់ធ្លាប់បានទទួលដីកាសម្រេចដាក់ឲ្យស្ថិតក្រោមការពិនិត្យ និងដីកាជូនដំណឹងអំពីបទចោទប្រកាន់ដែលអមទៅជាមួយដោយរួមមានព័ត៌មានក្នុងនោះ មេធាវីគឺត្រូវស្ថិតនៅក្រោមករណីយកិច្ចនៃក្រមសីលធម៌ក្នុងការផ្ដល់ និងពិភាក្សាអំពីព័ត៌មាននេះជាមួយនឹងកូនក្ដីរបស់ខ្លួន ហើយមេធាវីមិនធ្លាប់បានផ្ដល់នូវការបញ្ជាក់ណាមួយថាខ្លួនមិនដែលបានធ្វើដូច្នោះម្ដងណាឡើយ។ ជាចុងបញ្ចប់ តាមរយៈមេធាវីការពារក្ដីរបស់គាត់ គាត់មាន មធ្យោបាយចូលមើលនូវរាល់ភស្តុតាងនៅក្នុងសំណុំរឿង ក៏ដូចជាមានសិទ្ធិក្នុងការស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរ និងការជំទាស់ទៅនឹងសេចក្ដីសម្រេចនានារបស់ កសចស ផងដែរ[31]។

21. អាស្រ័យហេតុដូច្នេះ វិធាន ១០៤ នៃតុលាការ STL បានឆ្លុះបញ្ចាំងពីតថភាពដែល *រាល់សិទ្ធិទាំងអស់* ដែលបានស្វែងរកដើម្បីឲ្យបាននូវកិច្ចធានាចំពោះជនជាប់ចោទ ដោយការតម្រូវឲ្យមានវត្តមានផ្ទាល់របស់គាត់នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌនោះ គឺច្បាស់ជាត្រូវបានធានាយ៉ាងពិតប្រាដនៅពេលដែលគាត់ត្រូវបានតំណាងដោយមេធាវីការពារក្ដីប្រកបទៅដោយគុណវុឌ្ឍិ ទៅតាមការជ្រើសរើសរបស់គាត់ផ្ទាល់នោះ ជាមួយនឹងមេធាវីដែលគាត់បានធ្វើការប្រាស្រ័យទាក់ទងហើយគាត់បានផ្ដល់ការណែនាំទៅកាន់មេធាវីនោះ[32]។ ដោយសារតែការតំណាងឲ្យបែបដូច្នេះ បាន

---

[28] **D122/11** ដីកាសម្រេចទទួលស្គាល់មេធាវីតំណាងជនសង្ស័យ អ៊ឹម ចែម, ២៤ កុម្ភៈ ២០១៤។ **D122/13/1** ដីកាសម្រេចទទួលស្គាល់សហមេធាវីអន្តរជាតិតំណាង អ៊ឹម ចែម, ២ ឧសភា ២០១៤។ ដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ, កថាខណ្ឌ ៧៤។

[29] *សូមអាន ឧទា.,* ដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ, កថាខណ្ឌ ៦០។

[30] បណ្ដឹងឧទ្ធរណ៍, ក៏ដូចជាសំណើផ្សេងៗទៀតដែលបានដាក់ដោយមេធាវីការពារក្ដី អ៊ឹម ចែម ដូច្នោះដែរ, បានលើកឡើងថាត្រូវបានដាក់ជូនដោយ "លោកស្រី អ៊ឹម ចែម តាមរយៈសហមេធាវីការពារក្ដីរបស់គាត់" បណ្ដឹងឧទ្ធរណ៍, កថាខណ្ឌ ១។

[31] ដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ, កថាខណ្ឌ ៧៣។ វិធាន ៥៥(១០), ៥៨(៦) និង ៧៤(៣) នៃវិធានផ្ទៃក្នុង។

[32] *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* Cassese បានពិភាក្សាអំពីការជំនុំជម្រះ *ដោយកំបាំងមុខ* យ៉ាងវែង ហើយបានពិនិត្យពីសនិទានភាពនៅក្រោមវិធានទាំងនោះដែលបានអនុញ្ញាត និងបានហាមឃាត់ដល់ការជំនុំជម្រះបែបដូច្នោះ។ *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិរបស់*

ដកហូតចេញនូវគ្រោះថ្នាក់នៃកិច្ចដំណើរការនីតិវិធី *ដោយអវត្តមាន* នៅក្នុងស្ថានភាពដែលជនជាប់ចោទណាម្នាក់ត្រូវបានតំណាងឲ្យបែបដូច្នេះ នោះគឺមិនសមស្របទាល់តែសោះក្នុងការនិយាយ ឬវិភាគពីកិច្ចដំណើរការនីតិវិធីមួយថា *ដោយអវត្តមាន* ។

22. ពិតហើយ ដូចដែល សចសអ បានរកឃើញយ៉ាងត្រឹមត្រូវដូច្នោះដែរ វិធាន និងច្បាប់យុត្តិសាស្ត្រនៃតុលាការ STL ក៏បានអនុញ្ញាតផងដែរឲ្យមានកិច្ចដំណើរការនីតិវិធីមួយដែលនៅក្នុងនោះ ជនជាប់ចោទមិនមានវត្តមានយ៉ាងពិតប្រាកដ គឺថាជាកិច្ចដំណើរការនីតិវិធីមួយដែលនៅក្នុងនោះ ជនជាប់ចោទមិនបានមកបង្ហាញខ្លួនដោយផ្ទាល់ ឬមួយដោយតាមរយៈមេធាវីនោះ[33]។ ទាំងនេះគឺស្ថិតនៅក្រោមកិច្ចធានានៃកិច្ចដំណើរការនីតិវិធីមួយចំនួន ដែលបានតាក់តែងឡើងដើម្បីផ្តល់ដល់ជនជាប់ចោទដែលមិនមានវត្តមាន នូវឱកាសដ៏ល្អបំផុតដែលអាចសិក្សាពីបទចោទនានា និងដើម្បីឲ្យមេធាវីការពារក្តីបានការពារផលប្រយោជន៍របស់ខ្លួន[34]។ ប៉ុន្តែការធានាដោយកិច្ចដំណើរការនីតិវិធីទាំងនេះ ត្រូវបានតាក់តែងឡើងដោយគ្រាន់តែទំនងជាធ្វើឲ្យជនជាប់ចោទទទួលបាននូវសិទ្ធិ និងផលប្រយោជន៍នានា ដែលអង្គជំនុំជម្រះនេះអាចមានការច្បាស់លាស់ហួសវិមតិសង្ស័យដែល អ៊ឹម ចែម ទទួលបានរួចទៅហើយ៖ សិទ្ធិក្នុងការបានដឹងពីបទចោទនានា និងភស្តុតាងប្រឆាំងនឹងរូបគាត់ ព្រមទាំងសិទ្ធិក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីតាមរយៈមេធាវីការពារក្តីដែលបានជ្រើសរើសដោយខ្លួនគាត់ផ្ទាល់។ និយាយម្យ៉ាងវិញទៀត អ៊ឹម ចែម និងផលប្រយោជន៍របស់គាត់ គឺអាចបង្ហាញបានតាមឋានៈដែលបានការពារបានច្រើនជាងជនជាប់ចោទនៅតុលាការ STL។ គេនិយាយបានទៀតថា ការចោទប្រកាន់លើរូបគាត់ គឺត្រូវតាមវិធាននីតិវិធីដែលបានបង្កើតឡើងនៅទីនោះ។

*Cassese,* ការបោះពុម្ពផ្សាយលើកទី៣, Antonio Cassese *និងគូកន* eds, សារព័ត៌មាននៃសាកលវិទ្យាល័យ Oxford, ២០១៣ (“*Cassese’s ICL*”), ទំព័រ ៣៥៧-៣៦២។ គេកត់សម្គាល់ថា វិធានដែលតម្រូវឲ្យមានវត្តមានរបស់ជនជាប់ចោទនៅពេលជំនុំជម្រះក្តី “កើតចេញមកពីសិទ្ធិរបស់ជនជាប់ចោទក្នុងពេលតទល់ជាមួយនឹងសាក្សីនានាដែលប្រឆាំងនឹងគាត់” ហើយគេកត់សម្គាល់ថា តុលាការ ICTY និង ICTR បានយកគំរូតាម, “ដោយបានសង្កត់ធ្ងន់ ជាពិសេសលើតួនាទីរបស់ជនជាប់ចោទនៅក្នុងការចូលរួមយ៉ាងមានប្រសិទ្ធិភាពនៅក្នុងកិច្ចការពារដោយខ្លួនគាត់ផ្ទាល់”, *Cassese’s ICL*, ទំព័រ ៣៥៧។ គេកត់សម្គាល់បន្តទៀតថា កាលណាផលប្រយោជន៍ទាំងនេះត្រូវបានការពារ នោះជនជាប់ចោទមិនទទួលរងនូវការបាត់បង់សិទ្ធិដែលកើតចេញមកពីការអវត្តមានរបស់គាត់នោះទេ។ ជាពិសេស រឿងនេះគឺនៅក្នុងករណីដែលកាលណាអវត្តមានកើតឡើងដោយចេតនា ហើយកាលណាជនជាប់ចោទអាចនឹងប្រើប្រាស់នូវសិទ្ធិរបស់ខ្លួនក្នុងការបង្ហាញខ្លួននៅពេលណាមួយក៏បាន។

[33] ដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ, កថាខណ្ឌ ៥០-៥៤។

[34] ដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ, កថាខណ្ឌ ៥០-៥៤។

*៤. នៅក្រោមយុត្តិសាស្ត្រតុលាការសិទ្ធិមនុស្សអឺរ៉ុប, ដោយសារការជូនដំណឹងទាន់ពេលវេលារបស់គាត់ អំពីកិច្ចដំណើរការនីតិវិធី និងការចូលរួមតាមរយៈក្រុមមេធាវីការពារក្តី, អ៊ឹម ចែម ត្រូវបានចាត់ទុកថាបានចូលមកបង្ហាញខ្លួននៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ ឬបានលះបង់សិទ្ធិមិនចូលមកបង្ហាញខ្លួនរួចជាស្រេចទៅហើយ។*

23. យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប គាំទ្រចំពោះគំនិតក្នុងវិធាន១០៤ របស់ STL ដែលចែងថា បុគ្គលដែលបានបង្ហាញខ្លួនក្នុងកិច្ចដំណើរការនីតិវិធី តាមរយៈមេធាវីការពារក្តីតាមការជ្រើសរើសរបស់ខ្លួន "គឺការពិតមិនអវត្តមាន" នៅក្នុងទិដ្ឋភាពផ្លូវច្បាប់មានអត្ថន័យទេ។ រឿងក្តីដែលបានពឹងផ្អែកដោយ សចស អន្តរជាតិ គឺរឿងក្តី *Lala ទល់នឹងប្រទេសហូឡង់*[35] បង្កប់ន័យថា ការជជែកដេញដោលគ្នាទាំងមូលទាក់ទងនឹងការជំនុំជម្រះ *ដោយកំបាំងមុខ* អាចមិនពាក់ព័ន្ធឡើយ នៅពេលដែលជនជាប់ចោទត្រូវបានផ្តល់ការជូនដំណឹងទាន់ពេលអំពីកិច្ចដំណើរការនីតិវិធី និងការចូលរួមក្នុងកិច្ចដំណើរការតាមរយៈមេធាវីដែលខ្លួនបានជ្រើសរើស និងណែនាំ។

24. ជនជាប់ចោទក្នុងរឿងក្តី *Lala,* ក៏ដូច អ៊ឹម ចែម ដែរ ត្រូវបានផ្តល់ការជូនដំណឹងអំពីនីតិវិធីប្រឆាំងនឹងគាត់ និងត្រូវបានធ្វើតំណាងដោយមេធាវីការពារក្តីតាមការជ្រើសរើសរបស់គាត់ ដូចគ្នានឹង អ៊ឹម ចែម ដែរ គឺគាត់បានចូលរួមយ៉ាងសកម្មក្នុងកិច្ចដំណើរការនីតិវិធី ដែលប្រឆាំងនឹងរូបគាត់តាមរយៈមេធាវី[36]។ គាត់បដិសេធមិនចូលរួមកិច្ចដំណើរការនីតិវិធីទាំងនេះដោយផ្ទាល់ ដោយសារគាត់នឹងត្រូវចាប់ខ្លួនចំពោះបញ្ហាមួយផ្សេងទៀតដែលមិនពាក់ព័ន្ធ ហើយគាត់ខ្លាចគេចាប់ខ្លួនពេលគាត់ចូលបង្ហាញខ្លួនដោយផ្ទាល់នៅតុលាការ[37]។ ដោយសារតែការខកខានមិនបានចូលបង្ហាញខ្លួនដោយផ្ទាល់របស់ *Lala* ទើបតុលាការហូឡង់បានសម្រេចថា មេធាវីរបស់គាត់ត្រូវបានហាមឃាត់មិនឱ្យ

[35] *Lala ទល់នឹងប្រទេសហូឡង់,* តុលាការសិទ្ធិមនុស្សអឺរ៉ុប, ពាក្យសុំលេខ 14861/89, ២២ កញ្ញា ១៩៩៤ ("Lala")។ សេចក្តីសម្រេចចោទប្រកាន់, កថាខណ្ឌ៤៩ & កំណត់សម្គាល់ជើងទំព័រលេខ៥៣។

[36] *Lala*, កថាខណ្ឌ១០-១២។

[37] *Lala,* កថាខណ្ឌ១០។

ធ្វើតំណាងការពារក្តីឲ្យ *Lala* និងចូលរួមក្នុងសាលក្រមកំបាំងមុខប្រឆាំងរូបគាត់[38]។ តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុបបានសម្រេចថា វាជាការរំលោភទៅលើអនុសញ្ញាអ៊ឺរ៉ុប ចំពោះការមិនអនុញ្ញាតឲ្យមេធាវីធ្វើជាតំណាងការពារក្តីឲ្យ *Lala* ដោយគ្រាន់តែ ដោយសារ *Lala* អវត្តមានដោយស្ម័គ្រចិត្តពីកិច្ចដំណើរការនីតិវិធី[39]។ ប៉ុន្តែ តុលាការនេះគាំទ្រដោយមិនច្បាស់ចំពោះសេចក្តីអះអាងថា បើមេធាវីរបស់ *Lala* ត្រូវបានអនុញ្ញាតឲ្យការពារក្តី *Lala* នោះគ្មានការរំលោភឡើយ បើទោះបីជាអវត្តមានដោយស្ម័គ្រចិត្តរបស់ *Lala* ក៏ដោយ[40]។

25. ដូច្នេះរឿងក្តី *Lala* ចោទជាសំណួរមួយ ថាតើការចោទប្រកាន់ អ៊ឹម ចែម ស្តាប់ទុកសមស្រប *ដោយកំបាំងមុខ* ក៏ដោយ។ នៅពេលចាប់ផ្តើមវិភាគរបស់ខ្លួន តុលាការក្នុងរឿងក្តី *Lala* បានថ្លែងថា៖

'តុលាការកត់សម្គាល់តាំងពីដើមដំបូងថា រឿងក្តីនេះ *មិនពាក់ព័ន្ធនឹងចំណោទថាតើ ការជំនុំជម្រះលើជនជាប់ចោទដោយកំបាំងមុខ សមស្របនឹងមាត្រា៦ កថាខណ្ឌ១ និង៣(គ) ដែរ ឬអត់នោះទេ... បណ្តឹងរបស់អ្នកដាក់ពាក្យសុំមិនមែនថា បណ្តឹងឧទ្ធរណ៍ត្រូវបានជំនុំជម្រះដោយអវត្តមានរបស់គាត់ឡើយ - គឺគាត់មិនបានប្រើប្រាស់សិទ្ធិក្នុងការចូលរួមរបស់គាត់ជាប្រយោជន៍...*[41] ។

26. ភាពស្មុគស្មាញពិតប្រាកដនៃសេចក្តីថ្លែងនេះគឺថា ជនជាប់ចោទដែលបានដឹងអំពីកិច្ចដំណើរការនីតិវិធីប្រឆាំងរូបគាត់ ហើយគាត់កំពុងតែចូលរួមតាមរយៈមេធាវីការពារក្តីរបស់គាត់ក្នុងដំណើរការនីតិវិធីទាំងនោះ ប៉ុន្តែយ៉ាងណាមិញគាត់មិនបាន "*ប្រើប្រាស់សិទ្ធិរបស់គាត់ក្នុងការចូលរួម*" ការពិត គឺមិន "អវត្តមាន" ឡើយ។ អវត្តមានជាក់ស្តែងរបស់គាត់ គឺគ្រាន់តែជាការលះបង់សិទ្ធិដែលមិនបានប្រាប់ត្រង់ៗដែលគាត់មាន ហើយគាត់បានដឹងថាគាត់មានសិទ្ធិនោះ ហើយគាត់បានជ្រើសរើសមិនប្រើប្រាស់សិទ្ធិនោះឡើយ។

---

[38] *Lala,* កថាខណ្ឌ១២។

[39] *Lala,* កថាខណ្ឌ៣៣-៣៤។

[40] *Lala,* កថាខណ្ឌ៣៣-៣៤។

[41] *Lala,* កថាខណ្ឌ៣០ (សង្កត់ន័យបន្ថែមដោយ *អក្សរទ្រេត*)។

27. រឿងក្តីទីពីរ គឺរឿងក្តី Sejdović តទល់នឹងប្រទេសអ៊ីតាលី[42] ដែលត្រូវបានយកមកសំអាងដោយ សចស អន្តរជាតិនោះ ក៏បានបង្ហាញអំពីស្ថានភាពនានាដែលបុគ្គលម្នាក់អាចត្រូវបានជឿជាក់ថា បានបោះបង់សិទ្ធិមិនមានវត្តមានរបស់ខ្លួននៅក្នុងកិច្ចដំណើការនីតិវិធីប្រឆាំងនឹងរូបគាត់។ នៅក្នុង រឿងក្តី *Sejdović* តុលាការបានកំណត់គោលការណ៍ថា "ទាំងសំណេរ និងស្មារតីនៃមាត្រា៦ នៃ អនុសញ្ញាមិនបានហាមបុគ្គលណាម្នាក់ មិនឲ្យលះបង់ឆន្ទៈរបស់ខ្លួន *ទោះជាស្តែងឲ្យឃើញ ច្បាស់លាស់ ឬស្ងៀមស្ងាត់ក៏ដោយ* ដែលជាសិទ្ធិទទួលបានការធានាលើការជំនុំជម្រះក្តីដោយ យុត្តិធម៌"[43]។ (ប្រយោគនេះមាននៅក្នុងផ្នែករងក្រោមចំណងជើងថា "ការលះបង់សិទ្ធិមិនបង្ហាញ ខ្លួនក្នុងសវនាការ" និងក្នុងបរិបទនេះ ច្បាស់ពាក់ព័ន្ធនឹងសិទ្ធិមានវត្តមាន)។ បន្ទាប់មកតុលាការ បន្តលើកឡើងថា ដើម្បីឲ្យមានប្រសិទ្ធភាព ការលះបង់សិទ្ធិនេះ "ត្រូវតែធ្វើឡើងដោយឥតមន្ទិល និងធ្វើឡើងក្នុងន័យទទួលបានការធានាជាអប្បបរមាសមស្របទៅនឹងសារៈសំខាន់របស់វា" ហើយ ថាការលះបង់នេះមិនត្រូវផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈឡើយ[44]។

28. នៅក្នុងការពិភាក្សារបស់ខ្លួនពីវិធីសម្រេចថាតើ ការលះបង់សិទ្ធិមិនមានវត្តមាន ត្រូវតែធ្វើឡើង ដោយឥតមន្ទិល ឬអត់ តុលាការបានលើកឡើងថាខ្លួនបានសម្រេចពីមុនមកថា "ដើម្បីជូនដំណឹង ដល់អ្នកណាម្នាក់អំពីការចោទប្រកាន់ប្រឆាំងនឹងរូបគាត់ គឺជាសកម្មភាពផ្លូវច្បាប់សំខាន់ ដែលត្រូវ តែអនុវត្តស្របតាមលក្ខខណ្ឌតម្រូវនៃនីតិវិធី និងជាសារធាតុ ដែលអាចធានាដល់ការអនុវត្តមាន ប្រសិទ្ធភាពដល់សិទ្ធិរបស់ជនជាប់ចោទ។ ភាពមន្ទិលសង្ស័យ និងការដឹងឮក្រៅផ្លូវការមិនអាច គ្រប់គ្រាន់ឡើយ"[45]។ ប៉ុន្តែតុលាការក៏បានបញ្ជាក់ច្បាស់ផងដែរថា ចំណុចសំខាន់នោះគឺឲ្យជនជាប់ ចោទបាន*ដឹងឮពិតប្រាកដ*អំពីកិច្ចដំណើការនីតិវិធី មិនមែនទម្រង់ជាក់លាក់ណាមួយនៃការជូន ដំណឹងផ្លូវការនោះឡើយ។ ជនជាប់ចោទដែលបានដឹងឮពិតប្រាកដ ហើយនៅតែខកខានមិនមាន វត្តមាន នឹងត្រូវចាត់ទុកថាអវត្តមានដោយស្ម័គ្រចិត្ត៖

> ទោះជាយ៉ាងណាក៏ដោយ តុលាការមិនអាចទាត់ចោលលទ្ធភាពដែលថាអង្គហេតុដែលបានបង្ហាញ មួយចំនួនអាចផ្តល់នូវការចង្អុលបង្ហាញច្បាស់លាស់ថា ជនជាប់ចោទបានដឹងពីអត្ថិភាពនៃកិច្ច

---

[42] *រឿងក្តី Sejdović តទល់នឹង ប្រទេសអ៊ីតាលី,* ពាក្យសុំលេខ 56581/00, ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០០៦ ("*Sejdović*"), ត្រូវបាន យោងក្នុងជើងទំព័រលេខ ៥២ នៃដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ។

[43] *Sejdović,*កថាខណ្ឌ៨៦ (ឯកសារយោងត្រូវបានលុប) (គូសបញ្ជាក់បន្ថែម)។

[44] *Sejdović,* កថាខណ្ឌ៨៦ (ឯកសារយោងត្រូវបានលុប)។

[45] *Sejdović,* កថាខណ្ឌ៩៩ (ឯកសារយោងត្រូវបានលុប)។

ដំណើរការនីតិវិធីព្រហ្មទណ្ឌនានាប្រឆាំងនឹងរូបគាត់ និងដឹងពីលក្ខណៈ និងមូលហេតុនៃការចោទប្រកាន់ ហើយ *មិនមានបំណងចូលរួមក្នុងការជំនុំជម្រះក្តី ឬមានបំណងគេចវេសពីការចោទប្រកាន់។ ឧទាហរណ៍ នេះអាចជាករណីដែលជនជាប់ចោទថ្លែងជាសាធារណៈ ឬជាលាយលក្ខណ៍អក្សរថា គាត់មិនមានបំណងឆ្លើយតបទៅនឹងដីកាកោះ* ដែលរូបគាត់បានដឹងតាមរយៈប្រភពនានា ជាជាងតាមរយៈអាជ្ញាធរ ឬជោគជ័យក្នុងការគេចវេសពីការប៉ុនប៉ងនាំខ្លួន *ឬនៅពេលដែលឯកសារត្រូវបានជូនដំណឹងដល់អាជ្ញាធរដែលត្រូវបានបង្ហាញយ៉ាងច្បាស់ថា គាត់ដឹងអំពីកិច្ចដំណើរការនីតិវិធីដែលកំពុងរង់ចាំប្រឆាំងនឹងរូបគាត់ និងដឹងអំពីបទចោទប្រកាន់ដែលរូបគាត់ត្រូវប្រឈមមុខ។*[46]

29. យ៉ាងច្បាស់នោះ ដូចដែលបានពិចារណាដោយតុលាការក្នុងរឿងក្តី *Sejdović* អ៊ឹម ចែម ខ្លួនឯងបានធ្វើសេចក្តីថ្លែងជាសាធារណៈបង្ហាញថារូបគាត់ដឹងពីបទចោទប្រកាន់ប្រឆាំងនឹងគាត់ និងថាគាត់មានចេតនាគេចវេសពីកិច្ចដំណើរការនីតិវិធីប្រសិនបើគាត់អាចធ្វើបាន។ នៅក្នុងបទសម្ភាសន៍ជាមួយសារព័ត៌មាន *Cambodia Daily* អ៊ឹម ចែម បាននិយាយថា "ខ្ញុំពិតជាមិនទទួលយក [ការចោទប្រកាន់] ទេ។ ខ្ញុំមិនបានធ្វើអ្វីខុសនោះទេ។ អ្នកណាក៏ដោយដែលចោទប្រកាន់ខ្ញុំ សូមទៅយកពួកគេ ហើយដាក់គុកពួកគេទៅចុះ។"[47] អត្ថបទទាំងឡាយនៅក្នុងសារព័ត៌មាន *Phnom Penh Post* បង្ហាញថាប្តីរបស់គាត់ និងសមាជិកគ្រួសាររបស់គាត់ ក៏បានដឹងអំពីការចោទប្រកាន់ទាំងនេះដែរ ហើយដឹងថាគាត់បានលក់ដី បានទិញរថយន្ត និងបានចាកចេញពីផ្ទះក្រោយពេលបានដឹងអំពីការចោទប្រកាន់ប្រឆាំងនឹងគាត់[48]។ អ៊ឹម ចែម ក៏បានផ្តល់បទសម្ភាសន៍ជាមួយនឹងវិទ្យុ VOA ជាភាសាខ្មែរផងដែរដែលក្នុងបទសម្ភាសន៍នោះគាត់បាននិយាយថា "គេចោទខ្ញុំខុសហើយ។ ខ្ញុំ

---

[46] *Sejdović,* កថាខណ្ឌ៩៩ (គូសបញ្ជាក់បន្ថែម ហើយឯកសារយោងត្រូវបានលុប)។

[47] អត្ថបទ "Former Khmer Rouge Officials Meet New Charges with Defiance"សារព័ត៌មាន *Cambodia Daily* ចេញផ្សាយថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ https://www.cambodiadaily.com/news/former-kr-officials-meet-new-charges-with-defiance-79133/, ត្រូវបានចូលមើលនៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៥។

[48] អត្ថបទ "Im Chaem Isn't Home", សារព័ត៌មាន *The Phnom Penh Post,* ចេញផ្សាយថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ http://www.phnompenhpost.com/im-chaem-isnt-home ត្រូវបានចូលមើលនៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៥។ អត្ថបទ "KRT Suspect Turns Up Ill in Tram Kak," សារព័ត៌មាន *The Phnom Penh Post,* ចេញផ្សាយថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ http://www.phnompenhpost.com/krt-suspect-turns-ill-tram-kak, ត្រូវបានចូលមើលនៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៥។

មិនបានធ្វើអ្វីខុសទេ។ ខ្ញុំនឹងមិនបង្ហាញខ្លួននៅតុលាការទេ។”[49] សេចក្តីថ្លែងទាំងនេះបង្ហាញថា អ៊ឹម ចែម ស្ម័គ្រចិត្តអវត្តមានពីកិច្ចដំណើរការនីតិវិធី ហើយដូច្នេះលះបង់សិទ្ធិមិនមានវត្តមានរបស់ខ្លួន។

### *5. ក្នុងទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមនុស្សដែលពឹងផ្អែកដោយ សចស អន្តរជាតិ អ៊ឹម ចែម អាចត្រូវបានចាត់ទុកថាបានលះបង់សិទ្ធិមិនមានវត្តមានរបស់ខ្លួន*

30. សចស អន្តរជាតិ បានពឹងផ្អែកយ៉ាងត្រឹមត្រូវលើទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមនុស្សក្នុងអានុភាពដូចគ្នា[50]។ នៅក្នុងទស្សនៈរបស់ខ្លួនស្តីពីរឿងក្តី *Mbenge តទល់នឹង Zaire* គណៈកម្មាធិការសិទ្ធិមនុស្សបាននិយាយថា៖

> “យោងតាមមាត្រា១៤(៣) នៃកតិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ [ICCPR] បុគ្គលគ្រប់រូបមានសិទ្ធិទទួលបានការជំនុំជម្រះដោយវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង និងតាមរយៈជំនួយផ្នែកច្បាប់។ បទប្បញ្ញត្តិនេះ និងលក្ខខណ្ឌតម្រូវផ្សេងទៀតនៃកិច្ចដំណើរការឆាប់រហ័សដូចមានចែងក្នុងមាត្រា១៤ មិនអាចត្រូវបានបកស្រាយក្នុងន័យ ដែលត្រូវតែធ្វើឱ្យកិច្ចដំណើរការនីតិវិធី *ដោយកំបាំងមុខ* មិនអាចទទួលយក ដោយមិនគិតដល់សម្អាងហេតុដែលជនជាប់ចោទអវត្តមានឡើយ។ តាមពិត នៅក្នុងកាលៈទេសៈខ្លះ កិច្ចដំណើរការនីតិវិធីដោយកំបាំងមុខ (*ឧទាហរណ៍ នៅពេលដែលជនជាប់ចោទបដិសេធមិនប្រើប្រាស់សិទ្ធមិនមានវត្ត ទោះបីជាត្រូវបានជូនដំណឹងគ្រប់គ្រាន់ជាមុនអំពីកិច្ចដំណើរការនីតិវិធីយ៉ាងណាក៏ដោយ*) កិច្ចដំណើរការនីតិវិធីដោយកំបាំងមុខ អាចអនុវត្តបានដើម្បីជាប្រយោជន៍ដល់កិច្ចការរដ្ឋបាលតុលាការឱ្យបានត្រឹមត្រូវ”[51]។

31. ទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមនុស្ស ស្របទៅនឹងវិធីសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប និងតុលាការ STL ៖ នៅពេលជនជាប់ចោទដឹងអំពីកិច្ចដំណើរការប្រឆាំងនឹងរូបគាត់ ហើយបានស្វះស្វែងរកគ្រប់មធ្យោបាយដើម្បីចូលរួម ប៉ុន្តែផ្ទុយទៅវិញនៅតែអវត្តមានដោយស្ម័គ្រចិត្ត គាត់មិនទទួលរងភាពអយុត្តិធម៌ ដោយសារការបន្តកិច្ចដំណើរការនីតិវិធីក្នុងពេលអវត្តមានរបស់គាត់ទេ។

---

[49] អត្ថបទ “Named Suspect Says She Will Not Cooperate With Tribunal”, សារព័ត៌មាន *VoA Khmer,* ចេញផ្សាយថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៥ http://www.voacambodia.com/content/named-suspect-says-she-will-not-cooperate-with-tribunal/2667421.html, បានចូលមើលនៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៥។

[50] ដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ កថាខណ្ឌ៤៧ ដោយយោងគណៈកម្មាធិការសិទ្ធិមនុស្ស រឿងក្តី *Daniel Monguya Mbenge តទល់នឹង. Zaire,* ឯកសារ អសប CCPR/C/18/D/16/1977, ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៨៣ (“*Mbenge តទល់នឹង Zaire*”), កថាខណ្ឌ១៤.១។

[51] *Mbenge តទល់នឹង Zaire*, កថាខណ្ឌ១៤.១ (គូសបញ្ជាក់បន្ថែម)។

បន្ថែមលើនេះទៀត វាពិតជាអយុត្តិធម៌ក្នុងការអនុញ្ញាតឱ្យគាត់ជ្រៀតជ្រែកផលប្រយោជន៍សង្គម ក្នុងកិច្ចការរដ្ឋបាលតុលាការឱ្យបានត្រឹមត្រូវ ដោយការបដិសេធមិនមានវត្តមានរបស់គាត់។

### *6. វិធាននីតិវិធីរបស់តុលាការ ICC អនុញ្ញាតឱ្យមានការបញ្ជាក់អំពីសវនាការស្តីពីបទចោទប្រកាន់ ដោយគ្មានជនជាប់ចោទដែលអវត្តមានដោយស្ម័គ្រចិត្ត*

32. សចស អន្តរជាតិ បានកំណត់យ៉ាងត្រឹមត្រូវអំពីសវនាការកំណត់បទចោទប្រកាន់ ដោយអនុលោមតាមមាត្រា៦១ នៃលក្ខន្តិកៈក្រុងរ៉ូមរបស់តុលាការ ICC ជានីតិវិធីសដៀងគ្នាក្នុងការជូនដំណឹងអំពីបទចោទប្រកាន់នៅ អ.វ.ត.ក[52]។ សវនាការកំណត់បទចោទនៅតុលាការ ICC គឺជាកិច្ចដំណើរការនីតិវិធីមុនអង្គសេចក្តី ដែលក្នុងកិច្ចដំណើរការនេះបុគ្គលម្នាក់អាចជំទាស់ការចោទប្រកាន់ តវ៉ានឹងភ័ស្តុតាងដែលបង្ហាញដោយអយ្យការ និងធ្វើការបង្ហាញភ័ស្តុតាង[53]។ វាមិននាំឱ្យមានការកំណត់លើការទទួលខុសត្រូវព្រហ្មទណ្ឌទេ តែវាជាការបញ្ជាក់ ឬជាការសម្រេចមិនបញ្ជាក់ពីការចោទប្រកាន់ ដែលព្រះរាជអាជ្ញាស្វែងរកបញ្ជូនទៅជំនុំជម្រះ[54]។

33. ខណៈដែលលក្ខន្តិកៈក្រុងរ៉ូមចែងថា ជាទូទៅ សវនាការបែបនេះត្រូវធ្វើឡើងក្នុងវត្តមានរបស់បុគ្គលដែលត្រូវចោទប្រកាន់ មានការលើកលែង ក្នុងករណីដែលបុគ្គលនោះបានលះបង់សិទ្ធិមិនមានវត្តមានរបស់ខ្លួន ឬ “បានភៀសខ្លួន ឬមិនអាចរកឃើញ ហើយដំណាក់កាលសមហេតុផលទាំងអស់ត្រូវបានធ្វើដើម្បីធានាថាគាត់បង្ហាញខ្លួននៅចំពោះមុខតុលាការ និងជូនដំណឹងដល់បុគ្គលនោះអំពីបទចោទប្រកាន់ និងថាសវនាការដើម្បីកំណត់បទចោទប្រកាន់ទាំងនោះ នឹងត្រូវធ្វើឡើង”[55]។ ក្នុងករណីនេះ សចស អន្តរជាតិ បានធ្វើគ្រប់ដំណាក់កាលសមហេតុផលទាំងអស់ ដើម្បីធានាឱ្យមានការបង្ហាញខ្លួនរបស់ អ៊ឹម ចែម ផ្ទាល់ ហើយបានជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំងនឹងរូបគាត់តាមរយៈមេធាវីការពារក្តីដោយជោគជ័យ។ ហេតុដូច្នេះ គាត់បានធ្វើគ្រប់ដំណាក់កាលដើម្បីការពារផលប្រយោជន៍ ដែលទាមទារឱ្យមានការការពារដោយមាត្រា៦១(២) នៃលក្ខន្តិកៈក្រុងរ៉ូមថាជាបុរេលក្ខខណ្ឌសម្រាប់ការធ្វើសវនាការបញ្ជាក់បទចោទប្រកាន់*ដោយកំបាំងមុខ*។

[52] ដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ កថាខណ្ឌ៥៦។

[53] លក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (“លក្ខន្តិកៈទីក្រុងរ៉ូម”) មាត្រា៦១។

[54] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា៦១។

[55] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា៦១(២)។

*7. សចស អន្តរជាតិ មិនមានកំហុសក្នុងការចេញដីកាសម្រេចដាក់ឲ្យស្ថិតក្រោមការពិនិត្យឡើយ*

34. តាមស្មារតីដែលមានពីមុនមក សចស អន្តរជាតិ បានធ្វើការសន្និដ្ឋានត្រឹមត្រូវថា អង្គហេតុនានានៃរឿងក្តីនេះបានបង្ហាញនូវបញ្ហាមួយដែលមិនអាចដោះស្រាយដោយវិធានផ្ទៃក្នុង ហើយបានវិភាគយ៉ាងត្រឹមត្រូវលើលើវិធាននីតិវិធីកម្ពុជាពាក់ព័ន្ធ និងវិធាននីតិវិធីត្រូវបានបង្កើតឡើងនៅកម្រិតអន្តរជាតិ។ ហេតុដូច្នេះ សចស អន្តរជាតិ មិនមានកំហុសក្នុងការចេញដីកាសម្រេចដាក់ឲ្យស្ថិតក្រោមការពិនិត្យនោះឡើយ។

*8. អ៊ឹម ចែម មិនទទួលរងភាពអយុត្តិធម៌ដែលបណ្តាលមកពីដីកាសម្រេចដាក់ឲ្យស្ថិតក្រោមការពិនិត្យនោះទេ*

35. ដូចបានពិភាក្សាខាងលើ ដីកាសម្រេចរបស់ សចស អន្តរជាតិ ចោទប្រកាន់ អ៊ឹម ចែម នោះ មិនបង្កើតឲ្យមានកំហុសនោះទេ។ យ៉ាងណាក៏ដោយ ពិតជាបង្កើតឲ្យមានកំហុសមែននោះ កំហុសនោះមិនអាចនាំឲ្យ អ៊ឹម ចែម ទទួលរងនូវភាពអយុត្តិធម៌ទេ។

36. អ៊ឹម ចែម តវ៉ាថាគាត់មិនមានវត្តមានដោយផ្ទាល់ នៅពេលជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំងនឹងរូបគាត់ ប៉ុន្តែជាលទ្ធផល គាត់មិនបានបង្ហាញឲ្យឃើញថាគាត់ស្ថិតក្នុងស្ថានភាពអាក្រក់ណាមួយនោះទេ។ តាមពិត ដីកាសម្រេចដាក់ឲ្យស្ថិតក្រោមការពិនិត្យនេះមិនធ្វើឲ្យ អ៊ឹម ចែម រងនូវភាពអយុត្តិធម៌នោះទេ តែបានផ្តល់អត្ថប្រយោជន៍ដល់រូបគាត់ទៅវិញ៖ ឥឡូវគាត់អាចចូលមើលសំណុំរឿងបាន និងមានសិទ្ធិក្នុងការស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរ និងជំទាស់នឹងដីកាសម្រេចនានារបស់ សចស អន្តរជាតិ[56]។

37. លើសនេះទៀត អ៊ឹម ចែម អាចលុបបំបាត់ភាពអយុត្តិធម៌ណាមួយ ដែលគាត់បានទទួលរង ដោយគ្រាន់តែរៀបចំចូលរួមក្នុងការបង្ហាញខ្លួនតាមវិធាន ៥៧ នៃវិធានផ្ទៃក្នុង ជាមួយនឹង សចស អន្តរជាតិ។ របៀបសរសេរក្នុងដីកាសម្រេចដាក់ឲ្យស្ថិតក្រោមការពិនិត្យ បង្ហាញយ៉ាងច្បាស់ថា សចស អន្តរជាតិ អាចរៀបចំឲ្យមានសវនាការបែបនេះនៅពេលណាមួយ។ ដូចគ្នានេះដែរ ប្រសិនបើគាត់មានបំណងធ្វើសេចក្តីថ្លែងអនុលោមតាមវិធាន៥៨ នៃវិធានផ្ទៃក្នុង។

## VI. ដំណោះស្រាយដែលស្នើឡើង

[56] ដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ កថាខណ្ឌ៧៣។ វិធាន៥៥(១០), ៥៨(៦) និង៧៤(៣) នៃវិធានផ្ទៃក្នុង។

38. មូលហេតុដូចបានលើកឡើងខាងលើ សហព្រះរាជអាជ្ញាសុំស្នើដោយគោរពឲ្យ អង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍នេះ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ | លោក **Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |